រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

# សេចក្តីសំរេចលេខ ១១ សសរ

## ស្តីពីការអនុញ្ញាតជាគោលការណ៍ឲ្យក្រុមហ៊ុន AZ Distribution Co., Ltd អភិវឌ្ឍន៍ និង ពង្រីកបន្ថែមនូវប្រព័ន្ធ និង សេវាទូរគមនាគមន៍ ជាតិទូទាំងព្រះរាជាណាចក្រកម្ពុជា

***

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨
- ក្នុងគោលដៅអនុវត្តគោលនយោបាយលើកទឹកចិត្តរបស់រាជរដ្ឋាភិបាល ចំពោះក្រុមហ៊ុនក្នុងស្រុក
- យោងលើសេចក្តីសំរេចលេខ ១៧ សសរ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ១៩៩៨
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៩

## សំរេច

**ប្រការ ១ :** អនុញ្ញាតឲ្យក្រុមហ៊ុន AZ Distribution Co., Ltd បានរាយបណ្តាញកាប្លិ៍អុបទិច (Fibre Optic Cable) ទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ២ :** អនុញ្ញាតឲ្យមានតែបណ្តាញកាប្លិ៍អុបទិចតែមួយ ដែលក្រុមហ៊ុន AZ Distribution Co., Ltd វិនិយោគក្នុងរយៈពេល ២៥ឆ្នាំ ។

**ប្រការ ៣ :** អនុញ្ញាតឲ្យក្រុមហ៊ុន AZ Distribution Co., Ltd ផ្តល់បណ្តាញទូរស័ព្ទ និងសេវាទិន្នន័យតាមបណ្តាខេត្ត-ក្រុង និងជនបទ ដូចបានរាយលំអិតនៅក្នុងគំរោងមេ (Master Plan) ក្នុងរយៈពេល ៧៥ឆ្នាំ គិតចាប់ពីឆ្នាំ ដែលប្រើប្រាស់ជាផ្លូវការ (Operational Year) ។

**ប្រការ ៤ :** អនុញ្ញាតឲ្យក្រុមហ៊ុន AZ Distribution Co., Ltd បានបន្តនិរន្តភាព ចំពោះសេវាច្រកចេញអន្តរជាតិ ក្រោយពេលផុតកិច្ចសន្យារបស់ TELSTRA នៅឆ្នាំ ២០០០ ។

**ប្រការ ៥ :** ក្រុមហ៊ុនត្រូវពង្រីកនូវសមត្ថភាពរបស់ច្រកចេញអន្តរជាតិ ដោយភ្ជាប់ផ្ទាល់ជាមួយកាប្លិ៍ក្រោមសមុទ្រ ឬ ជាមួយប្រព័ន្ធទំនើបផ្សេងៗទៀត ។

---

ប្រការ ៦ : ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ ត្រូវពិភាក្សាជាក់ស្តែងជាមួយក្រុមហ៊ុន បន្ថែមលើគោលការណ៍ដែលបានសំរេចរួចហើយ ដើម្បីឈានដល់ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងឲ្យបានឆាប់ ហើយជំរុញការអនុវត្តគំរោងនេះ ។

ប្រការ ៧ : ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងដែលពាក់ព័ន្ធ ក្រុមហ៊ុន AZ Distribution Co., Ltd មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

★★★

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

## សេចក្តីសំរេចលេខ ១២ សសរ

## ស្តីពីការផ្ទេរភារកិច្ច

* * *

### រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាល

### សំរេច

ប្រការ ១ : ផ្ទេរសិទ្ធិជូនឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្តីទី នៃរាជរដ្ឋាភិបាល ជំនួសសម្តេចនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅបំពេញទស្សនកិច្ចជាផ្លូវការ នៅសាធារណរដ្ឋប្រជាមានិតចិន ចាប់ពីថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ ១៩៩៩ រហូតដល់សម្តេចនាយករដ្ឋមន្ត្រី អញ្ជើញវិលនិវត្តមកកាន់មាតុប្រទេសវិញ ។